Commonwealth Department of Health and Aged Care

ANZFA Australia New Zealand Food Authority
TE MANA WHAKARITE KAI MŌ Ā ITEREIRIA ME AOTEAROA



ANZFA Factsheet Cambodian



# ក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារ- ប្រព័ន្ធប្រមូលយកម្ហូបអាហារមកវិញសំរាប់ម្ហូបអាហារគ្មានសុវត្ថិភាព

ជំពូកទី៣ (សំរាប់តែប្រទេសអូស្ត្រាលី)ច្បាប់ស្តីពីក្បួនខ្នាតខាងម្ហូបអាហារនៃអូស្ត្រាលី ញ៉ូវហ្សឺលិន

*កំណត់សំគាល់៖ ក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារថ្មីពុំអនុវត្តនៅក្នុងប្រទេសញ៉ូវហ្សឺលិនទេ ។ លក្ខខ័ណ្ឌដែលមាន ចែងក្នុងសិទ្ធិសញ្ញាក្បួនខ្នាតនៃម្ហូបអាហាររវាងប្រទេសអូស្ត្រាលីនិងញ៉ូវហ្សឺលិនពុំមានរាប់បញ្ចូលក្នុងក្បួនខ្នាត អនាម័យខាងម្ហូបអាហារទេ ។*

## តើនរណាដែលត្រូវការប្រព័ន្ធប្រមូលយកម្ហូបអាហារមកវិញ?

អ្នកលក់ដុំ, ឧស្សាហាករ, និងអ្នកនាំចូលត្រូវការប្រព័ន្ធប្រមូលយកម្ហូបអាហារមកវិញ ។ មូលហេតុសំរាប់ប្រមូលយកម្ហូបអាហារមកវិញអាចរាប់បញ្ចូលការចម្លងមេរោគនៃម្ហូបអាហារដោយការពុលម្ហូបអាហារដោយមេរោគបាក់តេរី ឬដោយជាតិគីមី ឬវត្ថុផ្សេងៗដែលអាចធ្វើឲ្យជនណាឈឺនៅពេលបរិភោគម្ហូបអាហារនោះ ។

ប្រសិនបើលោកអ្នកជាអ្នកលក់ដុំ, ជាឧស្សាហាករ, ឬអ្នកនាំចូលម្ហូបអាហារ, លោកអ្នកត្រូវតែមានប្រព័ន្ធប្រមូលយកម្ហូបអាហារ មកវិញដែលលោកអ្នកអាចប្រើសំរាប់យកម្ហូបអាហារមកវិញពីទីផ្សារ, ប្រសិនបើលោកអ្នកយល់ថាម្ហូបអាហារនោះអាចចម្លងមេរោគ តាមរបៀបណាមួយហើយអាចមានគ្រោះថ្នាក់នឹងការបរិភោគនៅក្រោយដែលលោកអ្នកបានបញ្ជូនវាតទៅឲ្យពាណិជ្ជកម្មម្ហូបអាហារឯទៀត ឬទៅអ្នកទិញរបស់លោកអ្នក ។ តម្រូវការនេះបានត្រូវគេកត់ទុកនៅក្នុងច្បាប់លេខ ៣.២.២ ប្រតិបត្តិសុវត្ថិភាពនៃម្ហូបអាហារនិងតម្រូវការទូទៅ (Under Standards 3.2.2 Food Safety Practices and General Requirements), ប្រព័ន្ធប្រមូលយកម្ហូបអាហារមកវិញត្រូវតែបញ្ជាក់ជាលាយលក្សណ៍អក្សរហើយលោកអ្នកត្រូវធ្វើតាមទម្រង់បែបបទ នៃការសរសេរជាលាយលក្សអក្សរនៅពេលមានការប្រមូលយកមកវិញនៃម្ហូបអាហារដែលគ្មានសុវត្ថិភាពនោះ។

ប្រសិនបើលោកអ្នកជាពាណិជ្ជកម្មខាងបំរើម្ហូបអាហារ ឬពាណិជ្ជកម្មលក់រាយ ដូចជា ផ្សារធំ, ភោជនីយដ្ឋាន ឬហាងលក់ ម្ហូបអាហារយកទៅក្រៅ, លោកអ្នកមិនត្រូវការប្រព័ន្ធប្រមូលយកម្ហូបអាហារមកវិញទេ, ប្រសិនបើលោកអ្នកមិនមែនជាអ្នក លក់ដុំ, ឬជាឧស្សាហាករ, ឬជាអ្នកនាំចូលផងដែរ ។ អ្នកលក់ដុំ, ឧស្សាហាករ, ឬអ្នកនាំចូលមានការទទួលខុសត្រូវខាងប្រមូល យកម្ហូបអាហារមកវិញនូវម្ហូបអាហារទាំងឡាយណាដែលលក់ទៅឲ្យផ្សារធំព្រមទាំងម្ហូបអាហារដែលលក់នៅក្នុងភោជនីយដ្ឋាន និងហាងលក់ម្ហូបអាហារយកទៅក្រៅ, ដែលជាធម្មតាត្រូវបានគេបរិភោគភ្លាមៗនោះ ជាមូលហេតុនាំឲ្យការប្រមូលយកម្ហូបអាហារ ពីកន្លែងទាំងនេះមកវិញពុំអាចអនុវត្តទៅបានស្រួលនោះទេ ។

យ៉ាងណាក៏ដោយ,ពាណិជ្ជកម្មបំរើម្ហូបអាហារនិងពាណិជ្ជកម្មលក់រាយប្រហែលជាត្រូវចូលរួមខ្លះៗនៅក្នុងប្រព័ន្ធប្រមូល យកមកវិញពីពាណិជ្ជកម្មឯទៀត ។ នៅក្នុងករណីនេះ តម្រូវការជាក់លាក់ខ្លះអនុវត្តទៅលើការបញ្ជាក់, ការទុកដាក់និង ការបោះចោលនៃម្ហូបអាហារដែលប្រមូលយកមកវិញនិងរបស់ដែលអតិថិជនយកមកឲ្យវិញ ។ ផ្នែកនៃក្រុជាសហេតុការណ៍ ដែលមានចំណងជើងថា "ការបោះចោលនៃម្ហូបអាហារដែលប្រមូលយកមកវិញ, ដែលគ្មានសុវត្ថិភាព, ដែលមិនសមរម្យ ឬម្ហូបអាហារដែលបញ្ជូនត្រឡប់មកវិញ"។ (Disposing of recalled, unsafe, unsuitalbe or returned food), មានបញ្ចូលពត៌មានបន្ថែមស្តីពីតម្រូវការនេះ ។
ជួនកាលពាណិជ្ជកម្មម្ហូបអាហារសម្រេចប្រមូលយកមកវិញនូវម្ហូបអាហារដោយមូលហេតុដែលមិនទាក់ទងនឹងសុវត្ថិភាពនៃម្ហូបអាហារនោះទេ, ឧទាហរណ៍, កំហុសពីកញ្ចប់ ឬផ្លាក; ហើយគេប្រហែលជ្រើសរើសយកប្រព័ន្ធប្រមូលយកមកវិញ របស់គេនោះមកប្រើ, ទោះបីជាវាគ្មានកាតព្វកិច្ចខាងផ្លូវច្បាប់សំរាប់គេធ្វើក៏ដោយ ។

## គោលបំណងនៃប្រព័ន្ធប្រមូលយកមកវិញ

ប្រព័ន្ធប្រមូលយកមកវិញត្រូវ ៖

- បញ្ឈប់យ៉ាងឆាប់ដែលអាចធ្វើទៅបាននូវការចែកបន្តទៅទៀតនិងការលក់ដូរផលិតផលគ្មានសុវត្ថិភាព;
- ប្រាប់សាធារណៈជននិងអាជ្ញាធរទាក់ទិននិងប្រព័ន្ធនេះស្តីពីបញ្ហាដែលកើតឡើង; ហើយនិង
- ប្រមូលយកមកវិញដោយប្រសិទ្ធិភាពនូវម្ហូបអាហារគ្មានសុវត្ថិភាព ។

## ចំណុចសំខាន់ពិសេសៗនៃប្រព័ន្ធប្រមូលយកមកវិញ

ប្រព័ន្ធប្រមូលយកមកវិញត្រូវបញ្ចូលចំណុចសំខាន់ពិសេសដូចតទៅនេះ ៖

- គោលដៅនៃការប្រមូលយកមកវិញនិងបញ្ជីឈ្មោះសមាជិកនៃក្រុមអ្នកប្រមូលយកមកវិញនិងការទទួលខុសត្រូវរបស់គេ;

 **ការបកប្រែភាសានេះបានទទួលការឧបត្ថម្ភទាំងស្រុងពីក្រសួងសហព័ន្ធខាងសុខភាពនិងការ ថែរក្សាមនុស្សចាស់**

Health and Aged Care

ANZFA
Australia New Zealand **Food** Authority
TE MANA WHAKARITE KAI MŌ Ā ITEREIRIA ME AOTEAROA



- វិធានការមួយចំនួនដើម្បីណែនាំសេចក្តីសម្រេចលើគ្រោះថ្នាក់ទាក់ទិននឹងផលិតផលដែលអាចគ្មានសុវត្ថិភាព ។
- វិធានការមួយចំនួនសំរាប់ណែនាំសេចក្តីសម្រេចលើទំហំនៃការប្រមូលយកមកវិញ-ឧទាហរណ៍, តើផលិតផលបានបញ្ជូនទៅឲ្យដល់ដៃអ្នកលក់រាយ និងលក់ទៅដល់អថិតិជនហើយឬនៅ ។
- បញ្ជីអាជ្ញាធរដែលគេត្រូវប្រាប់ពីបញ្ហាប្រមូលយកមកវិញ, ឧទាហរណ៍, អាជ្ញាធរខាងម្ហូបអាហារអូស្ត្រាលី ញ៉ូវហ្សេឡិន (ANZFA)និងរដ្ឋមន្ត្រីសហព័ន្ធ និងរដ្ឋនិងដែនដី ដែលទទួលខុសត្រូវចំពោះសុខភាព, ក្រសួងកិច្ចការអ្នកប្រើប្រាស់និងពាណិជ្ជកម្មនៅក្នុងរដ្ឋនិងដែនដីដែលផលិតផលទាំងនោះបានត្រូវគេចែកចាយឲ្យលក់ដូរ ។
- បញ្ជីទីកន្លែងដែលផលិតផលបានចែកចាយ, ឧទាហរណ៍, ទៅដល់អ្នកលក់ដុំ, មជ្ឈមណ្ឌលសំរាប់ចែកចាយ, ផ្សារធំ, មន្ទីរពេទ្យនិងភោជនីយដ្ឋាន;
- បញ្ជីពត៌មានដែលនឹងជួយដល់ពាណិជ្ជកម្មដ៏ទៃទៀតនិងសាធារណៈឲ្យដឹងពិស្តារពីមុខម្ហូបអាហារនោះនិងបញ្ជូនម្ហូបអាហារដែលអ្នកកំពុងប្រមូលនោះយកមកវិញ, ឧទាហរណ៍, ឈ្មោះផលិតផល, លេខកូតនៃបាច់, ថ្ងៃខែ, ហេតុដែលប្រមូលយកមកវិញ, ទីកន្លែងដែលត្រូវយកមកវិញ ហើយនិងឈ្មោះអ្នកដែលត្រូវទាក់ទងដើម្បីយកពត៌មានបន្ថែម;
- ការរៀបចំសម្រួលឲ្យមានការប្រមូលយកម្ហូបអាហារត្រឡប់មកផ្សារធំ ឬសាខាដ៏ទៃទៀត; ហើយនិង
- ការរៀបចំសម្រួលដើម្បីស្ទង់មើលចំនួនម្ហូបអាហារដែលបានប្រមូលយកមកវិញមានប៉ុន្មានទៀតដែលនៅសល់ក្នុងទីផ្សារ ។

## កូនសៀវភៅណែនាំដែលមានសំរាប់ជួយបញ្ហាប្រមូលយកមកវិញ

កូនសៀវភៅណែនាំសំរាប់ការប្រមូលយកមកវិញមានពីរប្រភេទដោយឥតគឺតថ្លៃពី ANZFA

ពិធីការប្រមូលយកម្ហូបអាហារមកពីឧស្សាហកម្ម The Food Industry Recall Protocol (កំពុងពិនិត្យឡើងវិញ) និងជួយលោកអ្នកនូវកិច្ចការដែលត្រូវធ្វើក្នុងពេលប្រមូលយកមកវិញនិងផ្តល់ពត៌មានពិស្តារថែមទៀតស្តីពីប្រភេទនៃពត៌មានដែលគួររាប់បញ្ចូលនៅក្នុងប្រព័ន្ធប្រមូលយកមកវិញ ។

ពិធីការប្រមូលយកមកវិញនៃអាជ្ញាធរសុខភាពរដ្ឋាភិបាលផ្តល់ចំណុចសំខាន់ៗនៃការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងបញ្ហាប្រមូលយកមកវិញ ។

## ការចោលនូវម្ហូបអាហារដែលប្រមូលយកមកវិញ, ដែលគ្មានសុវត្ថិភាព, ដែលគ្មានសមរម្យ ឬដែលយកត្រឡប់មកវិញ

ពាណិជ្ជកម្មម្ហូបអាហារទាំងអស់ត្រូវធ្វើឲ្យប្រាកដថា ម្ហូបអាហារដែលត្រូវបានគេប្រមូលយកមកវិញត្រូវបានទុក, ដាក់ដោយកត់ចំណាំឲ្យបានច្បាស់លាស់និងរក្សាទុកវាដោយឡែកពីម្ហូបអាហារដ៏ទៃទៀត ។ នេះគឺដើម្បីជៀសវាងការលក់ដូរម្ហូបអាហារនោះដោយចៃដន្យ ។ លោកអ្នកត្រូវទុកនិងរក្សាម្ហូបអាហារនោះដោយឡែកពីគេរហូតដល់លោកអ្នកទទួលបញ្ជារពីក្រុមហ៊ុនប្រមូលយកម្ហូបអាហារទៅវិញនិងប្រាប់លោកអ្នកនូវអ្វីខ្លះដែលត្រូវធ្វើ, ឬប្រសិនបើវាជាម្ហូបអាហារលោកអ្នកប្រមូលយកមកវិញនោះ, ត្រូវទុករហូតដល់លោកអ្នកបានសម្រេចលើការបោះចោលម្ហូបអាហារទាំងនោះ ។

## តើត្រូវការពត៌មានបន្ថែមទៀតឬទេ?

អត្ថបទនៃក្បួនខ្នាត, ការណែនាំលើអ្វីទាំងអស់នេះ, និងក្រដាសហេតុការណ៍ដ៏ទៃទៀតនិងឯកសារគាំទ្រអាចរកបាននៅតាមវែបសៃ(www.anzfa.gov.au)។

នៅពេលដែលក្បួនខ្នាតនេះនឹងអនុវត្តនៅក្នុងរដ្ឋនិងដែនដីនិមួយៗ, ពាណិជ្ជកម្មម្ហូបអាហារក៏នឹងអាចរកឱវាទផ្ទាល់បានពីភ្នាក់ងារសុខភាពខាងបរិស្ថាននៅតាមសាលាសង្កាត់គេ; ឬពីក្រសួង សុខភាពរដ្ឋ ឬដែនដីគេ ឬ ក្រសួងកិច្ចបំរើខាងសុខភាពនិងក្រុមសុខភាពសាធារណៈ ។

ពត៌មានពិស្តារសំរាប់ទាក់ទងក្រសួងសុខភាពរដ្ឋនិងដែនដីនិងសាលាសង្កាត់លោកអ្នកមានបញ្ចូលនៅក្នុងក្រដាសហេតុការណ៍នៃក្បួនខ្នាតសុវត្ថិភាពនៃម្ហូបអាហារ-ប្រភពពត៌មាននិងឱវាទ (Food Safety Standards-Source of information & advice).

Australia New Zealand Food Authority
P O Box 7186
Canberra MC ACT 2610
Tel: 02 6271 2222 Fax: 02 6271 2278

Website: www.anzfa.gov.au
Email: advice@anzfa.gov.au
Advice Line: 1300 652 166

Australia New Zealand Food Authority
P O Box 10559
Wellington NZ 6036
Tel: 04 473 9942 Fax: 04 473 9855

Website: www.anzfa.govt.nz
Email: nz.reception@anzfa.gov.au
Advice Line: 0800 441 571